# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍន៍
## របៀបវារៈទី IIA: ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច និងជម្រើសគោលនយោបាយ
## ថ្លែងដោយ លោក ចន នែម (John Nelmes) តំណាង IMF ប្រចាំកម្ពុជា
## តំណាងដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣
## ភ្នំពេញ ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១០

*សូមគោរព ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!*

ឯកឧត្តម លោកជំទាវ លោក លោកស្រីៈ

សូមអនុញ្ញាតឱ្យខ្ញុំថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានអញ្ជើញយើងខ្ញុំឱ្យចូលរួមក្នុងវេទិកាអភិវឌ្ឍន៍និងសហប្រតិបត្តិការកម្ពុជា (CDCF) នាឆ្នាំនេះ និងសូមអរគុណចំពោះឱកាសដើម្បីថ្លែងនូវការកត់សម្គាល់មួយចំនួនអំពីការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយ។ CDCF ពិតជាប្រព្រឹត្តទៅចំពេលវេលាដ៏មានសារៈសំខាន់។ ជាមួយនឹងការងើបឡើងនៃសេដ្ឋកិច្ចពិភពលោកបន្ទាប់ពីការធ្លាក់ចុះដ៏ធ្ងន់ធ្ងរកាលពីពេលថ្មីៗកន្លងទៅនេះ និងសញ្ញាដែលបង្ហាញថាកម្ពុជាក៏កំពុងងើបឡើងវិញដែរនោះ ឥឡូវនេះគឺជាពេលវេលាដ៏វិសេសវិសាល ក្នុងការដកស្រង់នូវមេរៀនកាលពីពេលកន្លងទៅថ្មីៗនេះ និងផ្តោតការយកចិត្តទុកដាក់លើគោលនយោបាយនានា ដែលនឹងជួយប្រទេសកម្ពុជាឱ្យវិលត្រលប់ទៅកាន់មាគ៌ាកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយចីរភាព ព្រមទាំង លើកកំពស់សុខភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាផងដែរ។

ទិន្នន័យបានបង្ហាញថាកាលពីឆ្នាំមុនសេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះ ធ្វើឱ្យផលទុនជាតិសរុប ធ្លាក់ចុះប្រមាណ២,៥ ភាគរយ។ ទោះជាយ៉ាងណាក្តី ការងើបឡើងវិញបានចាប់ផ្តើមចាក់ឫសនៅចុងឆ្នាំ ២០០៩ ហើយបានបន្តទទួលបាននូវកម្លាំងចលករនៅឆមាសទីមួយនៃឆ្នាំ២០១០។ ការព្យាករណ៍ចុងក្រោយរបស់យើងគឺថាឆ្នាំនេះផលទុនជាតិសរុបមានអត្រាកំណើន៤,៧៥ភាគរយ ប្រហាក់ប្រហែលជាមួយអត្រាកំណើន តាមទស្សនវិស័យរបស់រាជរដ្ឋាភិបាលផងដែរ។ទន្ទឹមនឹងការងើបឡើងវិញនូវសកម្មភាពសេដ្ឋកិច្ចពិភពលោក ការនាំចេញសម្លៀកបំពាក់កំពុងត្រូវបានពង្រឹង ហើយការមកដល់នៃភ្ញៀវទេសចរកំពុងកើនឡើងខណៈដែលវិស័យសំណង់កំពុងចាប់ដំណើរការឡើងវិញ រីឯវិស័យកសិកម្មបន្តរីកចម្រើន។

ទស្សនវិស័យវិជ្ជមាននេះគឺជាដំណឹងដ៏ល្អសម្រាប់ប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក្តី ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកនេះ ទំនងជាមានកម្រិតទាបជាងការងើបឡើងវិញកាលពីពេលមុនៗ ហើយនៅតែមានបញ្ហាប្រឈមនិងហានិភ័យជាច្រើន។ បន្ថែមលើកំណែទម្រង់រចនាសម្ព័ន្ធនានាដើម្បីបង្កើនភាពប្រកួតប្រជែង និងពង្រីកមូលដ្ឋាននៃសកម្មភាពសេដ្ឋកិច្ច បញ្ហាប្រឈមមួយនៃបញ្ហាប្រឈមចំបងនានាផ្នែកសេដ្ឋកិច្ចចំពោះរាជរដ្ឋាភិបាលក្នុងពេលបច្ចុប្បន្នគឺការធានាយ៉ាងណាឱ្យការងើបឡើងនៃសេដ្ឋកិច្ចនេះមាននិរន្តរភាព ដោយមិនបង្កើតឱ្យមានសម្ពាធអតិផរណាសារជាថ្មី ឬមិនធ្វើឱ្យមានភាពងាយរងគ្រោះពីឥទ្ធិពលខាងក្រៅ។

ដើម្បីសម្រេចគោលដៅនេះបាន ចាំបាច់ត្រូវមានជំហានទៅកាន់ស្ថានភាពសារពើពន្ធ ដែលកាន់តែមានចីរភាព ដែលចាប់ផ្តើមបន្ថយវិសាលភាពឱនភាពថវិកានៃឆ្នាំមុន ហើយក្នុងរយៈពេលដ៏ខ្លីខាងមុខឈានទៅលុបបំបាត់ហិរញ្ញប្បទានក្នុងស្រុកដែលកំណើនហិរញ្ញប្បទាននេះបានបង្កើនបរិមាណប្រាក់រៀលជាសាច់ប្រាក់ងាយស្រួល ហើយអាចជម្រុញឱ្យមានអតិផរណា និងដាក់សម្ពាធមកលើអត្រាប្តូរប្រាក់ ប្រសិនបើគ្មានការដោះស្រាយទេនោះ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងយ៉ាងល្អក្នុងការពារការប្រមូលចំណូលបានល្អ ក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះ ហើយថវិកាឆ្នាំ២០១០ ប្រមើលឃើញថាបានទទួលកំណើនមួយចំនួន។ ទោះជាយ៉ាងណាក្តី កិច្ចប្រឹងប្រែងបន្ថែមទៀតក្នុងការកែលំអការគ្រប់គ្រងនិងពង្រីកមូលដ្ឋានចំណូល រាប់ទាំងការលុបបំបាត់ការលើកលែងពន្ធ និងលុបបំបាត់រយៈពេលមិនយកពន្ធ នឹងកាត់បន្ថយតម្រូវការក្នុងការផ្តល់ហិរញ្ញប្បទានក្នុងស្រុក ហើយផ្តល់លទ្ធភាពផ្នែកសារពើពន្ធ(fiscal space)ដល់ការចំណាយសម្រាប់វិស័យអាទិភាពនានា។ *តើមានការពិចារណាដែរឬទេអំពីការកាត់បន្ថយរយៈពេលមិនយកពន្ធ ខណៈដែលវាធ្វើប៉ះពាល់ជាអវិជ្ជមានចំពោះការប្រមូលចំណូល ហើយជាទូទៅ មិនធ្វើឱ្យមានពិពិធកម្មសេដ្ឋកិច្ចទូលំទូលាយឡើយ ?*

ជាមួយគ្នានេះដែរ ការកើនឡើងនូវឱនភាពសារពើពន្ធក៏បានឆ្លុះឱ្យឃើញនូវការកើនឡើងយ៉ាងលឿននូវកម្រិតចំណាយផងដែរ។ កំណើននេះមួយចំណែកមានទម្រង់ជាការបង្កើនចំណាយលើហេដ្ឋារចនាសម្ព័ន្ធ ដែលជួយទប់ការធ្លាក់ចុះនៃសេដ្ឋកិច្ច ហើយតទៅមុខការបង្កើនចំណាយបែបនេះនឹងរួមចំណែកដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងសក្តានុពលកំណើនសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក្តី កំណើនប្រាក់ខែយ៉ាងច្រើន និងកំណើនចំណាយការពារជាតិក៏រួមចំណែកផងដែរ។ ខណៈដែលតម្រូវឱ្យដោះស្រាយកម្រិតបៀវត្សរបស់រាជរដ្ឋាភិបាល ការតម្លើងប្រាក់ខែ គប្បីប្រព្រឹត្តទៅស្របគ្នាជាមួយវឌ្ឍនភាព នៃការងារកំណែទម្រង់មុខងារសាធារណៈ ដើម្បីកែលំអការផ្តល់សេវា។ ទន្ទឹមនេះដែរ ចាំបាច់ត្រូវយកចិត្ត ទុកដាក់ការពារការចំណាយលើវិស័យអាទិភាពនានា ដូចជាសុខាភិបាល និងអប់រំ ជាដើម។

កាន់តែមានលក្ខណៈទូលំទូលាយបន្ថែមទៀតនោះ មេរៀនមួយនៃមេរៀនសំខាន់ៗក្រោយវិបត្តិពិភពលោកគឺតម្រូវឱ្យមានការយកចិត្តទុកដាក់ដល់ថាមភាពបំណុលសាធារណៈ និងចីរភាពនៃបំណុលបរទេស។ ចំណុចនេះគឺជាការពិតជាពិសេសសម្រាប់បណ្តាប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកជាចំបងលើរូបិយប័ណ្ណបរទេស (ឬរូបិយប័ណ្ណរួម) ព្រោះថាក្នុងករណីបែបនេះគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយស្តីពីអត្រាប្តូរប្រាក់មិនមែនសុទ្ធមានតែអាចមានជាស្រេចដើម្បីជួយធ្វើឱ្យមានស្ថេរភាព និងការកែតម្រូវផ្នែកម៉ាក្រូសេដ្ឋកិច្ច នោះទេ។ អនុបាតបំណុលសាធារណៈរបស់ប្រទេសកម្ពុជាធៀបជាមួយ ផសស មានកម្រិតទាប ទោះជាយ៉ាងណាក្តី ដូចការវិភាគរួមគ្នាកាលពីពេលកន្លងទៅថ្មីៗរបស់មូលនិធិរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោកអំពីចីរភាពនៃបំណុល (Debt Sustainability Analysis) បង្ហាញថា យ៉ាងណា ក៏ដោយ គេឃើញមានហានិភ័យបន្ទុកបំណុលជាបង្គួរ ហើយក៏ឃើញមានសូចនាករមួយចំនួនជាសញ្ញាប្រាប់ ឱ្យប្រុងប្រយ័ត្នជាមុនផងដែរ។ ការវិភាគនោះក៏បង្ហាញផងដែរថា ការពន្យាពេលក្នុងការកាត់បន្ថយឱនភាព សារពើពន្ធ ឬការកើតឡើងនៃបំណុលយថាភាពរបស់រដ្ឋាភិបាល អាចប៉ះពាល់ជាអវិជ្ជមានចំពោះចីរភាពបំណុល និងប៉ះពាល់ដល់កិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ។

ក្រឡេកមើលកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈវិញ ដៃគូអភិវឌ្ឍន៍ស្វាគមន៍ចំពោះវឌ្ឍនភាពដែលសម្រេចបានជាបន្តបន្ទាប់លើផ្នែកមួយចំនួន និងគាំទ្រពេញទំហឹងចំពោះអភិក្រមរបស់រាជរដ្ឋាភិបាលក្នុងការផ្តោតការយកចិត្តទុកដាក់លើអនុសំណុំនៃវិធានការនានា ដើម្បីបង្កើនល្បឿនអនុវត្តដំណាក់កាលទីពីរនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការរៀបចំកញ្ចប់កំណែទម្រង់ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក នៅក្រសួងអាទិភាពពាក់ព័ន្ធមួយចំនួនតូច នឹងជួយប្រមូលផ្តុំធនធានកម្រឱ្យផលិតលទ្ធផលដែលមានចីរភាព ដែលមេរៀនពីការងារនេះអាចផ្សព្វផ្សាយដល់ការអនុវត្តក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ជាមួយគ្នានេះដែរ កិច្ចប្រឹងប្រែងក្នុងការពង្រឹងកំណែទម្រង់ ដែលលើកកំពស់ជំនឿទុកចិត្ត និងតម្លាភាពថវិកា គប្បីបន្តចាត់ទុកជាអាទិភាពខ្ពស់ ពិសេសក្នុងការគ្រប់គ្រង និងគណនេយ្យភាពចំពោះចំណូលដែលបានមកពី ឧស្សាហកម្មនិស្សារណកម្ម (Extractive industries) និងការបន្តកែលំអការងារចំណាត់ថ្នាក់ថវិកា គណនេយ្យរដ្ឋាភិបាល និងសមារណកម្មថវិកា។ ដៃគូអភិវឌ្ឍន៍សូមស្វាគមន៍ចំពោះព័ត៌មានបច្ចុប្បន្នភាពស្តីពីវិធានការនានា ដែលបានអនុវត្តដើម្បីបង្កើនតម្លាភាពក្នុងការរៀបចំថវិកា និងការរាយការណ៍ចំណូលដែលបានមកពីឧស្សាហកម្ម និស្សារណកម្ម។

សារៈសំខាន់មួយទៀតដែលបានមកពីបទពិសោធន៍អន្តរជាតិកាលពីពីរឆ្នាំមុនគឺថា ការត្រួតពិនិត្យធនាគារ និងការអនុវត្តបទប្បញ្ញត្តិប្រុងប្រយ័ត្នបានល្អ ធ្វើឱ្យមានហានិភ័យតិចជាងមុន និងធ្វើឱ្យវដ្តទាំងមូលនៃប្រព័ន្ធ

ហិរញ្ញវត្ថុកាន់តែមានស្ថេរភាព។ សម្រាប់ប្រទេសភាគច្រើន នេះគឺជាអំឡុងពេលដែលមានភាពប្រឈម ហើយជាទូទៅ ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងសភាពការណ៍បានល្អ។ កិច្ចប្រឹងប្រែងជាបន្ត ដើម្បីធ្វើយ៉ាងណាឱ្យធនាគារ នានាគោរពតាមកាតព្វកិច្ចរាយការណ៍ និងគោរពតាមកាតព្វកិច្ចនៃបទប្បញ្ញត្តិនានា គឺជាគន្លឹះក្នុងការការពារប្រព័ន្ធធនាគារ នៅពេលដែលវដ្តសេដ្ឋកិច្ចរីកចម្រើន។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលដែលបានផ្តល់ឱកាសចូលរួមនៅក្នុងកិច្ចពិភាក្សានានា នាព្រឹកនេះ។ តាងនាមឱ្យមូលនិធិរូបិយវត្ថុអន្តរជាតិ និងដៃគូរអភិវឌ្ឍន៍ទាំងអស់ សូមគូសបញ្ជាក់សារជាថ្មី ទៀត អំពីការបន្តកិច្ចប្រឹងប្រែងរបស់យើងចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងអំពីការប្តេជ្ញារបស់យើងក្នុងការជួយគាំទ្ររាជរដ្ឋាភិបាល ចំពោះកិច្ចប្រឹងប្រែងទាំងនេះ។